**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
ទទួល
លេខ 151
ថ្ងៃទី 23.08.2016
បញ្ជូន

លេខ ៧០៩៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែសីហា ឆ្នាំ ២០១៦

**ជម្រាបមក**

**-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល**

**-លោកប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស**

**កម្មវត្ថុ:** សំណើសហការជាមួយអាជ្ញាធរដែនដីរាជធានី ខេត្ត រៀបចំបែបបទ ផ្ទេរសម្រួលភារកិច្ចខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី ខេត្ត។

**យោង:** - អនុក្រឹត្យលេខ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា

- អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- សេចក្តីជូនដំណឹងលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលនិងលោកប្រធានជ្រាបថា យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងផ្អែកតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលនិងលោកប្រធានសហការជាមួយអាជ្ញាធរដែនដីរាជធានី ខេត្ត រៀបចំបែបបទផ្ទេរសម្រួលភារកិច្ចខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីឲ្យស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទន្ទឹមនេះ លោកប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវសហការជាមួយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលរដ្ឋបាលទាំងពីរ រៀបចំលិខិតបទដ្ឋានលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលឲ្យបានសមស្របតាមស្មារតីខាងលើជាបន្ទាន់។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលនិងលោកប្រធានចាត់ចែងអនុវត្តឲ្យបានរួចរាល់ហើយផ្ញើជូនក្រសួងវិញឲ្យបានមុនដំណាច់ខែសីហា ឆ្នាំ២០១៦ ដើម្បីក្រសួងមានវិធានការចាត់ការបន្តទាន់ពេលវេលាតាមការគួរ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- មន្ទីរកសិកម្មរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320